# ព្រះរាជក្រឹត្យ

នស/រកត/០២០២/០៥៥

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧៣ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការកំណត់អាណត្តិរបស់អភិបាល អភិបាលរង ខេត្ត ក្រុង និង អភិបាល អភិបាលរង ស្រុក ខ័ណ្ឌ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៩/២០៥ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការពន្យារអាណត្តិ សំរាប់អភិបាលរង ខេត្ត ក្រុង ទី ២ និង ទី ៣
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ : ត្រូវបានអនុញ្ញាតអោយពន្យារ អាណត្តិ ការងាររហូតដល់ ៥ ឆ្នាំ យ៉ាងយូរ គិតពីថ្ងៃដែលសាមីខ្លួន ត្រូវបានតែងតាំងសំរាប់មុខតំណែង អភិបាល អភិបាលរង ខេត្ត ក្រុង និង អភិបាល អភិបាលរង ស្រុក ខ័ណ្ឌ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី១ នេះ ។

មាត្រា ២ : ត្រូវទុកជានិរាករណ៍ នូវព្រះរាជក្រឹត្យលេខ នស/រកត/១១៩៩/២០៥ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : ៥៥ ច.ល

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ. ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២

៣រាស.០២.០២.០០៥៩

...ដើម្បីចម្លងចែក

រាជធានីភ្នំពេញ : ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

www.moj.gov.kh